**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ ២៨៥១៧ ....អពដ

GENERAL DEPARTMENT OF TAXATION

L202012290578 | TD2803

លេខ 1445
ថ្ងៃ 31.12.20 15h00

ថ្ងៃពុធ ១៥កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០២០

**គោរពជូន**

**ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី-ខេត្តទាំងអស់**

**កម្មវត្ថុ ÷** ស្តីពីការបន្តសុពលភាពលិខិតលេខ ៣៦៧ សជណ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីគោលការណ៍ពាក់ព័ន្ធនឹងពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យពុំបានចុះបញ្ជី (គ្មានប័ណ្ណកម្មសិទ្ធិ) និងការបន្តអនុគ្រោះបង់ពន្ធប្រថាប់ត្រាតែមួយដង ចំពោះការផ្ទេរកម្មសិទ្ធិអចលនទ្រព្យដែលបានចុះបញ្ជីរួច (មានប័ណ្ណកម្មសិទ្ធិ) ហើយបានផ្ទេរទាំងស្រុង ឬពុះឡូតិ៍ ឬបំបែកក្បាលដី បន្តដៃគ្នាពីម្នាក់ទៅដៃម្នាក់ច្រើនដង នៅត្រឹមថ្នាក់ឃុំ សង្កាត់ ឬក្រុង ស្រុក ខណ្ឌ ដែលបានធ្វើឡើងមុនឆ្នាំ២០១៧។

**យោង ÷**
- ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨ លើលិខិតលេខ ៣១៧៥ សហវ.អពដ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ លើលិខិតលេខ ១០៤៦៨ សហវ.អពដ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លិខិតលេខ ៣៦៧ សជណ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ១០០៧ សហវ.អពដ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត ជ្រាបថា រាជរដ្ឋាភិបាលបានសម្រេចបន្តសុពលភាពអនុវត្តពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យដែលបានចុះបញ្ជី (មានប័ណ្ណកម្មសិទ្ធិ) និងពុំបានចុះបញ្ជី (គ្មានប័ណ្ណកម្មសិទ្ធិ) និងពន្ធលើដីធ្លីមិនបានប្រើប្រាស់ ចំពោះអចលនទ្រព្យដែលពុំបានចុះបញ្ជី (គ្មានប័ណ្ណកម្មសិទ្ធិ) ដូចខាងក្រោម÷

១.បន្តសុពលភាពលិខិតលេខ ៣៦៧ សជណ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីគោលការណ៍ពាក់ព័ន្ធនឹងពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យពុំបានចុះបញ្ជី (គ្មានប័ណ្ណកម្មសិទ្ធិ) រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។ ចាប់ពីឆ្នាំ២០២២ តទៅនឹងត្រូវអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

២.បន្តអនុគ្រោះឱ្យបង់ពន្ធប្រថាប់ត្រាតែមួយដង ចំពោះការផ្ទេរកម្មសិទ្ធិអចលនទ្រព្យដែលបានចុះបញ្ជីរួច (មានប័ណ្ណកម្មសិទ្ធិ) ហើយបានផ្ទេរទាំងស្រុង ឬពុះឡូតិ៍ ឬបំបែកក្បាលដី បន្តដៃគ្នាពីម្នាក់ទៅដៃម្នាក់ច្រើនដង នៅត្រឹមថ្នាក់ឃុំ សង្កាត់ ឬក្រុង ស្រុក ខណ្ឌ ដែលបានធ្វើឡើងមុនឆ្នាំ២០១៧។ ការបន្តអនុគ្រោះឱ្យបង់ពន្ធតែមួយដងនេះ មានសុពលភាពអនុវត្តរហូតថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។ ចាប់ពីឆ្នាំ២០២២ តទៅ នឹងត្រូវអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

L202012290578 | TD2803

ការអនុគ្រោះនានាខាងលើនេះ មិនមានអានុភាពប្រតិសកម្មចំពោះប្រាក់ពន្ធ និងប្រាក់ទោសទណ្ឌផ្សេងៗ ដែលបានបង់រួចហើយនោះទេ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវអភិបាល ជ្រាប និងផ្សព្វផ្សាយតាមការគួរ។

សូមឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី-ខេត្តទាំងអស់ ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅ ពីខ្ញុំ

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

គង់ វិបុល

**ចម្លងជូន ÷**

- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

  "ដើម្បីគោរពជូនជ្រាប"
- ឯកឧត្តម លោកជំទាវ អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ
- នាយកដ្ឋានថ្នាក់កណ្តាល នៃអគ្គនាយកដ្ឋានពន្ធដារ
- សាខាពន្ធដារខេត្ត-ខណ្ឌ

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខ**...៣៦៧...សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សូមគោរពជូន**

- **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់**
- **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**
- **ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត**

**កម្មវត្ថុ ៖** ករណីសំណើសុំគោលការណ៍ពាក់ព័ន្ធនឹងពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យពុំបានចុះបញ្ជី (គ្មានប័ណ្ណកម្មសិទ្ធិ) ។

**យោង ៖** - លិខិតលេខ ៣១០៧ សហវ-អពដ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ឯកឧត្តមអភិបាល មេត្តាជ្រាបថា ដើម្បីពង្រឹង និងបង្កើនប្រសិទ្ធភាព ក្នុងការប្រមូលពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យពុំបានចុះបញ្ជី (គ្មានប័ណ្ណកម្មសិទ្ធិ) និងពន្ធលើដីធ្លីមិនបានប្រើប្រាស់ ដោយបញ្ចៀសនូវបញ្ហាប្រឈម និងភាពអសកម្មនានា រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចជាគោលការណ៍ និងវិធានការអនុវត្ត ដូចខាងក្រោម ៖

ក- ពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យពុំបានចុះបញ្ជី (គ្មានប័ណ្ណកម្មសិទ្ធិ) ៖

- ចំពោះការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យពុំបានចុះបញ្ជី (គ្មានប័ណ្ណកម្មសិទ្ធិ) ដែលបានផ្ទេរសិទ្ធិកាន់កាប់នៅថ្នាក់ឃុំ-សង្កាត់ ឬក្រុង-ស្រុក-ខណ្ឌ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ ត្រូវបានអនុញ្ញាតឲ្យបង់ពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិកាន់កាប់តាមដំណាក់កាលនីមួយៗ នៃការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យនោះ មានន័យថា មានការផ្ទេរសិទ្ធិកាន់កាប់មួយដង ត្រូវបង់ពន្ធប្រថាប់ត្រាមួយដង។ ជាមួយនេះ ត្រូវជំរុញឱ្យអ្នកកាន់កាប់អចលនទ្រព្យស្រាវទៅចុះបញ្ជីដំបូងនៅរដ្ឋបាលសុរិយោដី ដោយត្រូវភ្ជាប់នូវបង្កាន់ដៃបង់ពន្ធប្រថាប់ត្រានោះ

- ចំពោះអចលនទ្រព្យពុំបានចុះបញ្ជី (គ្មានប័ណ្ណកម្មសិទ្ធិ) ដែលបានផ្ទេរសិទ្ធិកាន់កាប់នៅថ្នាក់ឃុំ-សង្កាត់ ឬក្រុង-ស្រុក-ខណ្ឌ ដែលមានសាវតារផ្ទេរបន្តដៃគ្នាច្រើនដងមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ ហើយស្នើសុំចុះបញ្ជីដំបូងនៅរដ្ឋបាលសុរិយោដី អនុញ្ញាតឲ្យបង់ពន្ធប្រថាប់ត្រាតែមួយដងលើកចុងក្រោយ និងអនុញ្ញាតឲ្យដកចេញនូវមូលដ្ឋានគិតពន្ធប្រថាប់ត្រាចំនួន ៦០០ ០០០ ០០០ (ប្រាំមួយរយលាន) រៀល (សមមូល ១៥០ ០០០ ដុល្លារអាមេរិក)។ ការអនុញ្ញាតឱ្យដកចេញនូវមូលដ្ឋានគិតពន្ធនេះ មានសុពលភាពអនុវត្តត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ។ ចំពោះអចលនទ្រព្យដែលបានចុះបញ្ជីដំបូង ហើយត្រូវបានទទួលការអនុគ្រោះទោះបីជាមានប្រាក់ពន្ធស្មើ ០ (សូន្យ) រៀល ក៏ត្រូវអនុវត្តតាមនីតិវិធី និងបែបបទនៅរដ្ឋបាលសារពើពន្ធជាធរមាន ដើម្បីចុះបញ្ជី និងកត់ត្រាទិន្នន័យនូវអចលនទ្រព្យទាំងនោះ
- អាជ្ញាធរមូលដ្ឋានថ្នាក់ក្រោមជាតិ (ថ្នាក់ឃុំ-សង្កាត់ ឬក្រុង-ស្រុក-ខណ្ឌ) ត្រូវបញ្ជូនរាល់ករណីស្នើសុំផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យទាំងនោះ មកបំពេញបែបបទបង់ពន្ធប្រថាប់ត្រានៅរដ្ឋបាលសារពើពន្ធតាមច្បាប់ជាធរមាន
- លិខិតលេខ ១៣៤ សជណ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ ស្ដីពីវិធានការដោះស្រាយក្នុងការអនុវត្តប្រមូលពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ចំពោះអចលនទ្រព្យដែលបានចុះបញ្ជី និងពុំបានចុះបញ្ជី និងលិខិតលេខ ១៣៤៤ សជណ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ អំពីការពង្រឹងការគ្រប់គ្រងប្រមូលពន្ធប្រថាប់ត្រានៅរាជធានីភ្នំពេញ និងបណ្ដាខេត្តទាំង២៤ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ត្រូវទុកជានិរាករណ៍។

**ខ- ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ៖**

ចំពោះអចលនទ្រព្យពុំបានចុះបញ្ជី (គ្មានប័ណ្ណកម្មសិទ្ធិ) ដែលបានផ្ទេរសិទ្ធិកាន់កាប់នៅថ្នាក់ឃុំ-សង្កាត់ ឬក្រុង-ស្រុក-ខណ្ឌ ហើយជាកម្មវត្ថុនៃពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវបានអនុញ្ញាតឱ្យបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ចាប់ពីឆ្នាំទទួលសិទ្ធិកាន់កាប់ចុងក្រោយ ដោយផ្ដល់ការអនុគ្រោះឱ្យដកចេញនូវមូលដ្ឋានគិតពន្ធ ១០០ ០០០ ០០០ (មួយរយលាន) រៀល និងផ្ដល់ការលើកលែងប្រាក់ទោសទណ្ឌផ្សេងៗពាក់ព័ន្ធនឹងពន្ធនេះ។ ការអនុញ្ញាតឱ្យដកចេញនូវមូលដ្ឋានគិតពន្ធ និងប្រាក់ទោសទណ្ឌផ្សេងៗនេះ មានសុពលភាពអនុវត្តត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

ការអនុគ្រោះ និងការលើកលែងក្នុងចំណុច ក និង ខ ខាងលើ មិនមានអានុភាពប្រតិសកម្មចំពោះប្រាក់ពន្ធ និងប្រាក់ទោសទណ្ឌផ្សេងៗដែលបានបង់រួចហើយនោះទេ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមសម្ដេចក្រឡាហោម ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ឯកឧត្តមអភិបាល មេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

**ជ. រដ្ឋមន្ត្រីស្ដីទីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

Thoraxy

បណ្ឌិត **ហ៊ីង ថូរ៉ាក់ស៊ី**

**ចម្លងជូន ÷**

- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ឯកសារ-កាលប្បវត្តិ*